00810608

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 05 / 2012
ម៉ោង (Time/Heure): 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E172/25

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ៖ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២

**ជូនចំពោះ:** **ការិយាល័យរដ្ឋបាល; ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់ និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **សវនាការនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១២**

TRIAL CHAMBER · CHAMBRE DE PREMIÈRE INSTANCE · E C C C · E T C

បន្ថែមលើអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ ទាក់ទិននឹងការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មអ្នកជំនាញមួយចំនួនដែលភាគីបានស្នើសុំ (ឯកសារ E172/24) អង្គជំនុំជម្រះបានបញ្ជាក់ថាជាការចាំបាច់ដែលអង្គជំនុំជម្រះត្រូវធ្វើសវនាការនៅថ្ងៃ ពុធ ទី ១៧ ខែ តុលា ឆ្នាំ ២០១២ ដើម្បីបញ្ចប់ការស្តាប់សក្ខីកម្មរបស់លោកស្រី Elizabeth Becker។ វត្តមានរបស់លោកស្រី Becker គឺមានកំហិតក្រៃលែង ហើយការខកខានពុំបានធ្វើសវនាការនៅថ្ងៃនោះ នឹងប៉ះពាល់ដល់លទ្ធភាពរបស់អង្គជំនុំជម្រះក្នុងការបញ្ចប់ការផ្តល់សក្ខីកម្មរបស់គាត់ក្នុងពេលមួយដែលខ្លួនមាន។ ការខិតខំពុះពារដើម្បីស្វែងរកកាលបរិច្ឆេទមួយផ្សេងទៀតសម្រាប់ការផ្តល់សក្ខីកម្មរបស់លោកស្រី Becker ពុំទទួលបានជោគជ័យឡើយ។

បន្ទាប់ពីមានការសាកសួរទៅការិយាល័យរដ្ឋបាលនាពេលកន្លងមក អង្គជំនុំជម្រះបានទទួលដំណឹងថាថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១២ ពុំមែនជាថ្ងៃបុណ្យជាតិឡើយ។ អង្គជំនុំជម្រះបានទទួលការពន្យល់ជាបន្តបន្ទាប់ថា មានការបកស្រាយខុសៗគ្នា ពាក់ព័ន្ធទៅនឹងថាតើថ្ងៃនោះនឹងត្រូវបានប្រកាសជាស្ថាពរថាជាថ្ងៃបុណ្យជាតិដែរឬទេ។

អង្គជំនុំជម្រះសូមជូនដំណឹងទៅការិយាល័យរដ្ឋបាលថា ដោយសម្អាងតាមហេតុផលខាងលើ អង្គជំនុំជម្រះពុំមានជម្រើសអ្វីក្រៅពីត្រូវធ្វើសវនាការនៅថ្ងៃនោះឡើយ។ ក្នុងករណីមានការសម្រេចនៅពេលក្រោយថាថ្ងៃខាងលើគឺជាថ្ងៃបុណ្យជាតិ អង្គជំនុំជម្រះសូមស្នើថាបុគ្គលិកផ្នែកជាតិដែលត្រូវមកធ្វើការនៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១២ ដើម្បីផ្តល់សេវាដល់សវនាការ គួរទទួលបានការឈប់សម្រាកចំនួនមួយថ្ងៃនៅថ្ងៃផ្សេងជំនួសវិញ (ពិសេសនៅថ្ងៃ សុក្រ ណាមួយ ដែលជាថ្ងៃអង្គជំនុំជម្រះរមែងពុំធ្វើសវនាការ)។